ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨៤៤ អ.ក
ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១
សាលក្រមលេខៈ ៩៧ (ថ)
ចុះថ្ងៃទី០៦/១០/២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកកិច្ចពិភាក្សាដេញដោលជាសាធារណៈ នាសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ និងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោមៈ

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

## មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រដ្ឋា ហៅ ជា

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ា ហៅ ឡា ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ពេជ្រស្រី ពីន និងឈ្មោះ [redacted] វ៉ូនី ហៅ ចន

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហេងរដ្ឋា

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨៤៤ អ.ក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរអ្នកដឹកជញ្ជូន មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិបយាប សង្កាត់សែនសុខ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុណ្ណា (ស្លាប់) ម្តាយឈ្មោះ [redacted] ស្រីល័ក្ខ (ស្លាប់) នៅលីវ ជានីតិជនទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

២-ឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៦) ជនជាតិខ្មែរ មុខរបរអ្នកដឹកជញ្ជូន មានទីកន្លែងកំណើតភូ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ



Scanned with CamScanner

ឪពុកឈ្មោះ [redacted] សុខសុភា (រស់) ម្តាយឈ្មោះ [redacted] សាម៉ាន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៨ (ក្នុងឃុំ)

៣-ឈ្មោះ [redacted] រ៉ូនី ហៅ ចន ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៦) ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើតភូ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិគោកឃ្លៀង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សេត (ស្លាប់) ម្តាយឈ្មោះ [redacted] សុគន្ធធារី (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៨ (ក្នុងឃុំ)

៤-ឈ្មោះ [redacted] ពេជ្រស្រីពីន ភេទស្រី អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើតភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នរាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុខចាន់ (ស្លាប់) ម្តាយឈ្មោះ [redacted] សំអន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី១១ (ក្នុងឃុំ)

៥-ឈ្មោះ [redacted] ម៉ា ហៅ ឡា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នភូមិចុងព្រែក សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ធី (រស់) ម្តាយឈ្មោះ [redacted] ម៉ៃ (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី ១០ (ក្នុងឃុំ)

៦-ឈ្មោះ [redacted] វឌ្ឍនាថ ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិព្រែកធំ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សំណាង (រស់) ម្តាយឈ្មោះ [redacted] វាសនា (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី១១ (ក្នុងឃុំ)

៧-ឈ្មោះ [redacted] ស្រីកុល ភេទស្រី កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរ នៅផ្ទះ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ២១ សង្កាត់ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុផាត (រស់) ម្តាយឈ្មោះ [redacted] ធី (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

៨-ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិដើមចាន់ សង្កាត់ពុនសាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] មុន្នី (រស់) ម្តាយឈ្មោះ [redacted] សារ៉ុន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

៩-ឈ្មោះ [redacted] សុវិជ្ជា ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិអណ្តូង១ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឌីណា (រស់) ម្តាយឈ្មោះ [redacted] ធារុន (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

១០-ឈ្មោះ [redacted] ហេងរដ្ឋា ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកបរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រស់ (រស់) ម្តាយឈ្មោះ ជា ពៅ (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៧ (ក្នុងឃុំ)

១១-ឈ្មោះ [redacted] ម៉ាណែត ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិវាលស្បូវ សង្កាត់វាលស្បូវ ខណ្ឌច្បារ



Scanned with CamScanner

អំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] នឿន (រស់) ម្តាយឈ្មោះ [redacted] សាធី (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី១១ (ក្នុងឃុំ)

១២-ឈ្មោះ [redacted] ឈៀវ ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរនៅផ្ទះ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឈៀវ (រស់) ម្តាយឈ្មោះ [redacted] ឈាង (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

១៣-ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិស្វាយរលំ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សឿន (រស់) ម្តាយឈ្មោះ [redacted] ចន្ទី (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី១០ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១៤-ឈ្មោះ [redacted] សីហា ភេទប្រុស កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរជាងកាត់សក់ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុក (រស់) ម្តាយឈ្មោះ [redacted] ស្រីមុំ (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

១៥-ឈ្មោះ [redacted] រដ្ឋា ហៅ ជា ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិបោះអង្គាញ់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុនធឿន (រស់) ម្តាយឈ្មោះ [redacted] ម៉ាច (រស់) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងរដ្ឋប្បវេណី៖

១-ឈ្មោះ [redacted] ជីវ៉ុន ភេទស្រី អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

២-ឈ្មោះ [redacted] ស្រីមុំ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៣-ឈ្មោះ [redacted] បូលីន ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិរំដេញ ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល។

-បានឃើញមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រាបន្តបន្ទាប់។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០៥ និង៣០នាទី នៅផ្លូវជាតិលេខ១ ស្ថិតនៅភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កម្លាំងនគរបាលស្រុកកៀនស្វាយ បានប្រទះឃើញជនសង្ស័យពីរ

នាក់ ១ឈ្មោះ [redacted] ម៉ា ហៅក្រៅ ឡា ភេទប្រុស អាយុ១៧ឆ្នាំ និង២/ឈ្មោះ [redacted] វឌ្ឍនាថ ភេទប្រុស អាយុ១៧ឆ្នាំ បម្រុងធ្វើសកម្មភាពលួច(ឆក់) ទ្រព្យសម្បត្តិពីអ្នកដំណើរនៅចំណុចកើតហេតុខាងលើ ពេលនោះកម្លាំងនគរបាលស្រុកកៀនស្វាយបានឃាត់ខ្លួនជនសង្ស័យទាំងពីរនាក់ខាងលើសាកសួរ នៅចំពោះមុខសមត្ថកិច្ចជនសង្ស័យបានឆ្លើយសារភាព កាលពីអំឡុងខែកញ្ញា និងតុលា ឆ្នាំ២០២១ ពួកខ្លួនរួមជាមួយបក្ខពួក១៣នាក់ទៀត មានឈ្មោះ [redacted] សីហា ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៦ឆ្នាំ, ឈ្មោះ [redacted] រ៉ូនី ហៅក្រៅ ចន ភេទប្រុស អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៦ឆ្នាំ, ឈ្មោះ [redacted] សុបញ្ញា ហៅក្រៅ ញ៉ា ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] ឈៀវ ភេទប្រុស អាយុ១៧ឆ្នាំ. ឈ្មោះ [redacted] ម៉ាណែត ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] ស្រីកុល ភេទស្រី អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted] ពេជ្រស្រីពីន ភេទស្រី អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សុវិជ្ជា ភេទប្រុស អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted] ហេងរដ្ឋា ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ១៥ឆ្នាំ បានធ្វើសកម្មភាពលួច(ឆក់) យ៉ាងសកម្មនៅក្នុងភូមិសាស្ត្រខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងស្រុកកៀនស្វាយ ខេត្តកណ្ដាល ជាច្រើនដងមកហើយ។ ជាក់ស្ដែងនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២១ ម៉ោង០៥ និង២០នាទី នៅចំណុចភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក្រុមជនសង្ស័យខាងលើ បានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវីន ភេទស្រី អាយុ ២៦ឆ្នាំ បានទូរស័ព្ទ១គ្រឿង ប្រាក់ដុល្លា៩០$ និងប្រាក់ខ្មែរចំនួន ៤០០,០០០ (សែសិបម៉ឺនរៀល) និងនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ម៉ោង០៥ និង៣០នាទី នៅចំណុចភូមិព្រែកស្វាយ២ ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក្រុមជនសង្ស័យខាងលើ បានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន ភេទប្រុស អាយុ ២៨ឆ្នាំ បានប្រាក់ចំនួន ២០០០$(ពីរពាន់ដុល្លាអាមេរិក), ទូរស័ព្ទ២គ្រឿង និងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ម៉ោង១៩ និង៣៥នាទី នៅចំណុចភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក្រុមជនសង្ស័យខាងលើ បានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ បានប្រាក់ចំនួន ២០០$ (ពីររយដុល្លារអាមេរិក) និងទូរស័ព្ទ១គ្រឿង ។ ក្រោយពីបានចម្លើយសារភាពពីជនសង្ស័យ [redacted] ម៉ៅ និងឈ្មោះ [redacted] វឌ្ឍនាថ ភ្លាម នៅវេលាម៉ោង ១៤និង០០នាទី ថ្ងៃខែឆ្នាំដដែល កម្លាំងសមត្ថកិច្ចនគរបាលស្រុកកៀនស្វាយ ខេត្តកណ្ដាល សហការជាមួយកម្លាំងនគរបាលខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានចុះបង្ក្រាបឃាត់ខ្លួនជនសង្ស័យបានចំនួន១៣នាក់ខាងលើបន្ថែមទៀត នាំយកមកធ្វើការសាកសួរ និងតេស្តទឹកនោមឃើញថាជនសង្ស័យឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] សីហា មានវិជ្ជមានសារធាតុញៀនក្នុងខ្លួនផងដែរ។

- ក្រោយពីបានធ្វើកិច្ចពិភាក្សាដេញដោល
- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី [redacted]
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី [redacted]
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី [redacted]
- ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទទាំង១៥នាក់
- ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

# សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វ៉ូនី ហៅ ចន ឈ្មោះ ចាន់ ពេជ្រស្រីពីន ឈ្មោះ [redacted] ម៉ា ហៅ ឡា ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] វដ្ឋា ហៅ ជា ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមការពិនិត្យឯកសារ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងឃើញថា ពិតជាមានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វ៉ូនី ហៅ ចន ឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ [redacted] ម៉ា ហៅ ឡា ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ [redacted] វិសាល ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ និងឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] វដ្ឋា ហៅ ជា ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ ប្រាកដមែន។

២-ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វ៉ូនី ហៅ ចន ឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ [redacted] ម៉ា ហៅ ឡា ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ គឹម ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] វដ្ឋា ហៅ ជា មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ចំពោះមុខច្បាប់ពោល គឺជនជាប់ចោទ មិនមានសញ្ញាណាណាមួយដែលបង្ហាញថា ជនជាប់ចោទមានសតិវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដែលជាហេតុនាំមិនឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនឡើយ។

៣-អំពើរបស់ជនជាប់ចោទ៖

៣-១-ឈ្មោះ [redacted] វដ្ឋា យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនបានដឹងបទចោទខ្លួនហើយ។ មុនដំបូងខ្លួនចេញពីធ្វើការ ឈ្មោះ [redacted] ហេងវដ្ឋា បបួលខ្លួនដើរលេងទៅស្ពានអ្នកលឿងអង្គុយហូបអី ក៏មកវិញ បានឃើញឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] វិសាល។ ខ្លួនជិះម៉ូតូទៅជាមួយ ឈ្មោះ [redacted] ហេងវដ្ឋា និងឈ្មោះ [redacted] ម៉ាណែត ឆក់បានលុយចំនួន ១៥០០០ (មួយម៉ឺនប្រាំពាន់) រៀល និងទូរស័ព្ទអ៊ិនចុកពិលមួយគ្រឿង។ ពេលឆក់បានទៅចាំគ្នានៅផ្ទះសំណាក់។ ខ្លួនអត់ដែលឆក់ទេ លើកទីមួយដែលខ្លួនបានចូលរួម ក្រុមរបស់ខ្លួនអ្នកខ្លះខ្លួនស្គាល់យូរហើយ អ្នកខ្លះទៀតទើបតែស្គាល់ នៅក្នុងក្រុមជាមួយគ្នាខ្លួនមិនដឹងថាអ្នកណាខ្លះធ្វើសកម្មភាពអ្វីទេ។ ពេលទៅអ្នកលឿងជិះម៉ូតូបីគ្រឿង គ្នាប្រាំមួយនាក់ មានឈ្មោះ គឹម ម៉ាណែត ឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វិសាល ឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted]

ឈាវ ជាអ្នកបបួលខ្លួនទៅឆក់ តែខ្លួនអត់ទៅ។ ឈ្មោះក្រុមសាមគុក ឈ្មោះ [redacted] ហេងរដ្ឋា ជាមេក្រុម បង្កើតបាន៣ទៅ៤ខែហើយ ដើម្បីធ្វើចម្រៀង ក្រៅពីធ្វើចម្រៀង ទៅឆក់។ ខ្លួនពិតជាបានចេញឆក់យ៉ាងតិចបីដង ក្រុមខ្លួនមានចំនួន១៣នាក់ អត់ចេញឆក់ទាំងអស់ទេ ទៅម្តងបីម៉ូតូ អ្នកផ្សេងទៀតអត់ទៅទេ។ ថ្ងៃអត់ទៅ អត់បានលុយទេ ចេញលុយរៀងខ្លួន អ្នកចេញឆក់ចេញថ្លៃបន្ទប់ជួលរួមគ្នា ឈ្មោះ [redacted] ហេងរដ្ឋា និងឈ្មោះ [redacted] ម៉ាណែត ជាអ្នកចេញមុខជួលផ្ទះសំណាក់។ កន្លងមកធ្លាប់ចែកលុយគ្នាបានចំនួន២ទៅ៣ដង បានលុយចំនួនដំបូង៥០០០០ (ប្រាំម៉ឺន) រៀលទៅ ៣០០០០ (បីម៉ឺន) រៀល។ ពេលចេញធ្វើសកម្មភាពរាល់ដងខ្លួនអ្នកជិះពីក្រោយអ្នកឆក់ ក្រុមខ្លួនមានចំនួន១៣នាក់សុទ្ធតែធ្លាប់ធ្វើសកម្មភាពដូចគ្នា ក្នុងចំណោម១៣នាក់ អ្នកខ្លះអត់ដេកនៅក្នុងផ្ទះសំណាក់ទេ។ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ថា កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ម៉ោង១៨៖៤៥នាទី ខ្លួនជិះម៉ូតូ១គ្រឿង ឌុបក្មួយប្រុសឈ្មោះ [redacted] ឆានុន ចេញពីផ្ទះជួលនៅភូមិស្ពោកន្លែង២ ឃុំដីឥដ្ឋស្រុកកៀនស្វាយ ខេត្តកណ្តាល បំណងទៅផ្ទះម្តាយនៅភូមិអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល មកដល់ចំណុចដេប៉ូប្រេងតូតាល់ ភូមិខ្សុំ ឃុំបន្ទាយដែក មានជនមិនស្គាល់ម្នាក់ ពាក់អាវពណ៌ខ្មៅ ដៃវែង រាងស្គមខ្ពស់ ជិះម៉ូតូម៉ាក ហុងដា សេ១២៥ ស៊េរី២០២០ ពណ៌ខ្មៅ ស្លាកលេខមិនចាំ តែចាំស្លាលេខកន្ទុយ១៤ ជិះម៉ូតូមកពីក្រោយខ្លួនធ្វើសកម្មភាពឆក់កាបូបខ្លួន រួចជិះម៉ូតូមកដល់ផ្លូវចូលវត្តអង្គរជ័យ បត់ទៅផ្លូវលំភូមិកណ្តាលលើបាត់ទៅ។ នៅក្នុងកាបូបខ្ញុំមានប្រាក់ខ្មែរនិងប្រាក់ដុល្លារសរុប២០០$ ទូរស័ព្ទម៉ាក OPPO ចំនួនមួយគ្រឿង, អត្តសញ្ញាប័ណ្ណឈ្មោះ [redacted] បញ្ញា ភេទប្រុស, ប័ណ្ណ បសស ឈ្មោះ [redacted] ស្រីមុំ និងកាត់ ATM ធនាគារអេស៊ីលីដា របស់ឈ្មោះ [redacted] ស្រីមុំ។ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីស បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ថា កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ខ្លួននិងប្រពន្ធ បានទៅផ្ទះយកប្រាក់ ខ្ចីអង្គការ OLC នៅខេត្តស្វាយរៀង ចំនួន៣០០០$ ដោយដកសងថ្លៃដីអស់ចំនួន៥០០$ ដកសងពូអស់ចំនួន៥០០$ នៅសល់ប្រាក់ចំនួន២០០០$។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ម៉ោង៣៖០០នាទីយប់ ខ្លួន និងប្រពន្ធ ជិះម៉ូតូចេញពីផ្ទះមកធ្វើការងារ ដោយដាក់ប្រាក់ចំនួន២០០០$ និងទូរស័ព្ទ២គ្រឿងម៉ាក OPPO ក្នុងកាបូបស្ពាយ ដោយឱ្យប្រពន្ធខ្ញុំជិះពីក្រោយកាន់ស្ពាយកាបូបនោះ ធ្វើដំណើរតាមបណ្តាលផ្លូវជាតិលេខ១ បត់តាមផ្លូវជាតិលេខ១១៦A លុះដល់ចំណុចភូមិព្រែកស្វាយ២ ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ក៏ហានម៉ូតូម៉ាក ហុងដាសេ១២៥ ចំនួន១គ្រឿង ជិះគ្នាពីរនាក់ ភេទប្រុស មិនស្គាល់អត្តសញ្ញាណ បានឆក់កាបូបស្ពាយពីប្រពន្ធរបស់ខ្លួន រួចគេចខ្លួន ពេលនោះខ្លួនជិះម៉ូតូតាម តែមានម៉ូតូតាម តែមានម៉ូតូ១គ្រឿង ជិះគ្នាពីរនាក់ មកស្ទាក់បង្អាក់រូបខ្លួនមិនឱ្យតាម និងធ្វើឱ្យម៉ូតូខ្លួនដួលទៀតផង ហើយពួកវានាំគ្នាជិះម៉ូតូជិះគេចបាត់អស់ទៅ។ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ថា កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ម៉ោង៣៖០៥នាទី ខ្លួន និងប្តី ជិះម៉ូតូចេញពីខេត្តស្វាយរៀង មកធ្វើការនៅភូមិឈើទាល ឃុំឈើទាល ស្រុលកកៀនស្វាយ ខេត្តកណ្តាល ដល់ផ្លូវស្រែអំពិលល ភូមិព្រែកស្វាយ២ ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ម៉ោង០៥៖១០នាទីស្រាប់តែមានចោរទាំងពីរនាក់ អ្នកជិះពីមុខពាក់អាវខ្មៅ អ្នកជិះពីក្រោយពាក់អាវស ជិះម៉ូតូ១គ្រឿងម៉ាក ហុងដា សេ១២៥ មកអែមម៉ូតូខ្លួនខាងស្តាំដៃឆក់យកកាបូបស្ពាយរបស់ខ្លួនទៅបាត់ ពេលប្តីខ្លួនជិះម៉ូតូ១គ្រឿង ម៉ាក សងប៊ិច ពណ៌ខ្មៅ មានគ្នាពីរនាក់ ម្នាក់ពាក់អាវខ្មៅ កាន់ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ អ្នកអង្គុយក្រោយជាអ្នកកាន់ ពេលខ្លួនបុកអ្នកជិះម៉ូតូកាន់ខ្សែក្រវ៉ាត់ មិនបានមកបុកខ្លួន ហើយខ្លួនខំជួយដេញហើយបុកខ្លួនទៀត ស្រាប់តែមានម៉ូតូ១គ្រឿងទៀតមកឈប់មើលម៉ូតូឆក់ខ្លួនរួចហើយបើកម៉ូតូចេញបាត់។ កាបូបស្ពាយខ្លួនពណ៌ក្រហម មានប្រាក់ចំនួន២០០០$ និងប្រាក់ខ្មែរចំនួន២៣៧,៥០០រៀល អត្តសញ្ញាណប័ណ្ណ២សន្លឹក (ប្តីប្រពន្ធ) កាតចាក់វ៉ាក់សាំង និងកាតការងារមួយសន្លឹក។ តាម ចម្លើយរបស់ជន



Scanned with CamScanner

រងគ្រោះឈ្មោះ [redacted] ជីវ៉ុន បានឆ្លើយចំពោះមុខចៅក្រមស៊ើបសួរ ថា កាលពីថ្ងៃទី១៣ ខែមិនចាំ ឆ្នាំ២០២១ ម៉ោង ០៥៖២០នាទី គឺខ្លួនត្រូវជិះឡានទៅធ្វើការនៅរោងចក្រឈ្មោះ ហ្វ៊រគ្រេសអ៊ិនធើណាសិនណាល ឯ.ក នៅពេលនោះ ខ្លួនជិះម៉ូតូមកបំរុងឡើងឡានជិះមកកន្លែងធ្វើការ ស្រាប់តែឡានចេញចោល។ បន្ទាប់មកខ្លួនជិះម៉ូតូជាមួយប្តីមកកន្លែងធ្វើការ ជិះមកដល់ម្តុំភូមិខ្មុំ ស្រាប់តែមានមនុស្សពីរនាក់ ជិះមកធ្វើសកម្មភាពឆក់កាបូបពីខ្លួន យកទៅបាត់។ ក្នុងកាបូបមាន អត្តសញ្ញាណប័ណ្ណ កាតចាក់វ៉ាក់សាំង ប័ណ្ណ ប.ស.ស ទូរស័ព្ទមួយគ្រឿងលុយខ្មែរចំនួន២០ម៉ឺនរៀល និងលុយដុល្លារចំនួន១០០$។ ក្រោយពេលក្រុមចោរឆក់កាបូបខ្លួនហើយ ខ្លួនបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលបន្ទាយដែកតែម្តង។ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ថា កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង១៦៖២០នាទី ខ្លួនកំពុងនៅផ្ទះសំណាក់ ពេលនោះក៏មានបុរសម្នាក់រាងធាត់មាប់ ភេទប្រុស អាយុប្រហែល២០ឆ្នាំ ជិះម៉ូតូម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1TT-3077 បានមកបើកបន្ទបលេខB03 លុះព្រឹកឡើងក៏ចេញទៅវិញ ហើយបុរសម្នាក់នោះកក់បន្ទប់លេខB03 រហូតដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង០៧៖០០នាទីព្រឹក បុរសម្នាក់ម៉ាប់នោះចុះដឹកបុរសទៀតមកជាមួយ ជិះម៉ូតូខាងលើ មកដេកបន្ទប់B03 រហូតដល់ម៉ោង១១៖០០នាទីថ្ងៃដដែល ក៏មានសមត្ថកិច្ចនគរបាលច្បារអំពៅ និងសមត្ថកិច្ចខេត្តកណ្តាល ចុះមកឱ្យខ្លួនសហការបង្ហាញរូបថតមុខសញ្ញាឆក់មកឱ្យខ្លួនមើល ខ្លួននឹកឃើញថាបុរសដែលមានមាឌម៉ាប់ ដេកនៅបន្ទប់B03 ភ្លាមនោះខ្លួនក៏បានរាយការណ៍ជូនសមត្ថកិច្ចចុះមកចាប់ឃាត់ខ្លួនបុរសម្នាក់ម៉ាប់ និងមិត្តភក្តិគាត់ម្នាក់យកចេញបាត់ទៅ។

ជនជាប់ចោទឈ្មោះ ប៊ុណ្ណា រដ្ឋា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងតាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-២-ជនជាប់ចោទឈ្មោះ [redacted] ពៅ៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា មេក្រុមឈ្មោះ [redacted] ហេងរដ្ឋា និងឈ្មោះ [redacted] ម៉ាណែត។ ខ្លួនធ្លាប់ធ្វើសកម្មភាពបីដង នៅផ្លូវជាតិលេខមួយ អត់បានសម្រេច ជាមួយឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ម៉ា និងឈ្មោះ [redacted] វណ្ណនាថ។ លើកទីពីរ នៅផ្លូវជាតិលេខមួយដដែលអត់បានសម្រេច មានគ្នាដដែល និងលើកទីបី នៅផ្លូវជាតិលេខបី ជាមួយឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ម៉ាណែត នឹងឈ្មោះ [redacted] ហេងរដ្ឋា បិទគូទខ្លួន បានសម្រេចចែកលុយគ្នា ទូរស័ព្ទចែកគ្នាប្រើ។ បីករណីហ្នឹងក្នុងយប់តែមួយ។ ខ្លួនអត់មានក្រុមទេ អត់មានឈ្មោះក្រុមទេ យូៗដើរលេងម្តង។ ឈ្មោះ [redacted] រដ្ឋា ខ្លួនស្គាល់ ចំណែកឈ្មោះ [redacted] ម៉ាណែត ជាអ្នកនាំទៅឆក់ វាប្រាប់ថាចេញរកលុយ។ ឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted] វណ្ណនាថ ស្គាល់ រីឯឈ្មោះ [redacted] រ៉ូនី ឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ឈ្មោះ [redacted] ឈៀវ ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ម៉ា ខ្លួនអត់ស្គាល់ទេ តែឈ្មោះ [redacted] រដ្ឋា មួយអត់ចូលរួម។

ជនជាប់ចោទឈ្មោះ [redacted] ពៅ ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរង



Scanned with CamScanner

គ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ិ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា និងតាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពៅ ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-៣-ជនជាប់ចោទឈ្មោះ [redacted] វ៉ូនី ហៅ ចន៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនអត់ធ្លាប់ធ្វើសកម្មភាពទេ អត់នៅក្នុងក្រុមទេ ខ្លួនពិតទៅលេងផ្ទះសំណាក់ជាមួយស្រីៗ ខ្លួនទៅរៀន ឈ្មោះ [redacted] ពេជ្រ ស្រីពីន គេហៅខ្លួនទៅលេង ពេលទៅដល់មានគ្នាប្រាំនាក់ មានឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] សុបញ្ញា និងខ្លួន។ ឈ្មោះ [redacted] ឈៀវ ទៅដេកលេងនៅហ្នឹង ខ្លួនស្គាល់ឈ្មោះ [redacted] សុវិជ្ជា ស្រីៗអ្នកចំណាយសុំម៉ាក់ ឈ្មោះ [redacted] ស្រីកុល ឱ្យលុយខ្លួនទិញបាយរាល់ថ្ងៃ អត់ដឹងក្រុមគ្នាជាចោរទេ ដេកនៅផ្ទះសំណាក់ប្រហែលមួយអាទិត្យ ពេលដេកហ្នឹងឃើញ ឈ្មោះ [redacted] សុវិជ្ជា ចេញចូលបន្ទប់។ ឈ្មោះ [redacted] ហេងរដ្ឋា បបួលខ្លួនទៅឆក់ ខ្លួនអត់ទៅ អត់ដឹងថាគាត់ជាក្រុមឆក់ទេ ហើយមិនដែលចែកលុយទេ។ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ហេងរដ្ឋា ទេ គ្រាន់តែឃើញគាត់នៅជិតបន្ទប់ខ្លួន។

ជនជាប់ចោទឈ្មោះ [redacted] វ៉ូនី ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ ថ្វីត្បិតតែតាមចម្លើយរបស់ជនជាប់ចោទមិនសារភាព តែតាមចម្លើយរបស់ជនជាប់ចោទផ្សេងទៀត តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ិ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វ៉ូនី ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-៤-ជនជាប់ចោទឈ្មោះ [redacted] ពេជ្រស្រីពីន៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនអាយុ១៨ កើតឆ្នាំ២០០៤ ខែ១១ ថ្ងៃទី០៩ ខ្លួនគ្រាន់តែបកលេងសង្សារឈ្មោះ [redacted] សុវិជ្ជា គ្រាន់តែជួបគ្នាធម្មតា អត់ដឹងរឿងអីទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] វ៉ូនី និងឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted] ស្រីកុល ទើបបានជួបគ្នាក្នុងផ្ទះសំណាក់ មកផ្ទះសំណាក់ចេញលុយខ្លួនឯង ខ្លួននៅក្នុងបន្ទប់តែម្នាក់ឯង និងជាមួយស្រីម្នាក់ទៀត មិត្តភក្តិឈ្មោះ [redacted] វ៉ូនី ហៅឈ្មោះ [redacted] ស្រីកុល ឱ្យដេកជាមួយខ្លួន។ ខ្លួនអត់ដឹងពួកគាត់ឆក់ទេ ខ្លួនទៅផ្ទះសំណាក់ពីរដង ដេកបីយប់ ពេលខ្លួនទៅជួបសង្សារខ្លួន ខ្លួនដេកជាមួយឈ្មោះ [redacted] ស្រីកុល ខ្លួនទៅគេងតែពេលយប់ទេ ថ្ងៃឡើងដើរលេង។ ថ្ងៃចាប់ខ្លួន គេហៅខ្លួនទៅយកម៉ូតូពីផ្ទះសំណាក់តាខ្មៅ មកផ្ទះសំណាក់ច្បារអំពៅ គេចាប់ខ្លួនតែម្តង ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ហេងរដ្ឋា ទេ ខ្លួនទៅសេបគប់ក្រុមហ្នឹងតាមសង្សារខ្លួន។

ជនជាប់ចោទឈ្មោះ [redacted] ពេជ្រស្រីពីន ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ិ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]



Scanned with CamScanner

ពេជ្រស្រីពីន ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្ត អំពើហិង្សា ប្រាកដមែន។

៣-៥-ជនជាប់ចោទឈ្មោះ [redacted] ម៉ា ហៅ ឡា៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនដឹងបទចោទខ្លួនហើយ ដំបូងខ្លួនចេញពីកោះពេជ្រទៅកៀនស្វាយ ជិះម៉ូតូដើរលេង ខ្លួនជិះម៉ូតូអត់ទាន់ ត្រូវប៉ូលីសសុំឆែកនិងឃាត់ខ្លួន ទៅបំភ្លឺ ព្រោះម្ដុំហ្នឹងមានចោរឆក់ ប៉ូលីសសាកសួរ ក៏ឆ្លើយដាក់គ្នា ត្រូវបានប៉ូលីសចាប់មកទាំងអស់គ្នា។ ដំបូងខ្លួនជិះម៉ូតូទៅស្ពាង ជិះអត់ទាន់ខ្លួនក៏ឈប់ ទៅជាមួយឈ្មោះ មាស វឌ្ឍនាថ បួនម៉ូតូគ្នា៥នាក់ ឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] សុបញ្ញា ឈ្មោះ [redacted] ឈាវ ខ្លួនជិះជាមួយឈ្មោះ [redacted] វឌ្ឍនាថ។ ខ្លួនអត់បានឆក់ទេ ពួកគេធ្វើសកម្មភាពឆក់ម្ដុំផ្សារ ខ្លួនគ្រាន់តែធ្វើសកម្មភាពបិទគួទ ឈ្មោះ [redacted] ហេងរដ្ឋា ជាប្រធានក្រុម។ ក្រុមបង្កើតឡើងដើម្បីដើរលេង រាប់អានគ្នា ឈ្មោះក្រុមសាមកុក។ ខ្លួនកើតឆ្នាំ២០០៤។ ខ្លួនជាអ្នកបិទគួទឱ្យគេ គេអត់បានចែកលុយឱ្យទេ គ្រាន់តែគេប៉ាវស៊ីបាយ។ មុខចេញទៅឆក់បានប្រជុំគ្នា និងចាត់ចែងគ្នាមុន គឺឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ហេងរដ្ឋា។ អ្នកណាជួលផ្ទះសំណាក់ខ្លួនអត់ដឹងទេ រីឯឈ្មោះ [redacted] រ៉ូនី អត់ដែលធ្វើសកម្មភាពឆក់ជាមួយពួកខ្លួនទេ គាត់គ្រាន់តែដេកផ្ទះសំណាក់ជាមួយពួកខ្លួន និងដើរលេងជាមួយពួកខ្លួន ពេលធ្វើសកម្មភាពឆក់គាត់អត់ចូលរួមទេ គាត់នៅផ្ទះសំណាក់ជាមួយស្រីៗ គាត់ដេកទាំង១៤នាក់ មានពីរបន្ទប់ផ្សេងៗគ្នា បន្ទប់មួយរបស់ពួកស្រី។ ពីមុនខ្លួនអត់ដែលចេញធ្វើសកម្មភាពដល់ស្គាល់ឈ្មោះ [redacted] ហេងរដ្ឋា ទើបចេញធ្វើសកម្មភាព។

ជនជាប់ចោទឈ្មោះ [redacted] ម៉ា ហៅ ឡា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ ឃឹម ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ី តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ា ហៅ ឡា ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-៦- ជនជាប់ចោទឈ្មោះ [redacted] សុវឌ្ឍនាថ ៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ដំបូងខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ម៉ា និងឈ្មោះ [redacted] រដ្ឋា ខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] ម៉ា ឈ្មោះ [redacted] ម៉ាណែត ជិះជាមួយឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] រដ្ឋា ជិះជាមួយឈ្មោះ [redacted] សុវិជ្ជា បានពិភាក្សាគ្នារឿងបិទគួទ គឺខ្លួន និងឈ្មោះ [redacted] ម៉ា ឯឈ្មោះ វ៉េន ហេងរដ្ឋា និងឈ្មោះ [redacted] ម៉ាណែត អ្នកធ្វើសកម្មភាព។ ទើបធ្វើលើកទីមួយ ខ្លួន និងឈ្មោះ [redacted] ម៉ា ជិះទិញទឹកហូប ប៉ូលីសចាប់ខ្លួន និងឈ្មោះ [redacted] ម៉ា តាមផ្លូវមុន អ្នកផ្សេងគេចាប់នៅផ្ទះសំណាក់ ឈ្មោះ [redacted] ម៉ាណែត និងឈ្មោះ [redacted] ហេងរដ្ឋា ជាអ្នកឆក់។ ស្រីពីរនាក់ឈ្មោះ [redacted] ស្រីកុល និងឈ្មោះ [redacted] ពេជ្រស្រីពីន អត់ដែលធ្វើសកម្មភាព នៅតែផ្ទះសំណាក់។ អ្នកឆក់ហ្នឹងគឺ ឈ្មោះ [redacted] ម៉ាណែត និងឈ្មោះ [redacted] ហេងរដ្ឋា ឆ្លាស់ដូរគ្នា ឈ្មោះ [redacted] វិសាល ធ្លាប់ទៅធ្វើសកម្មភាព ឈ្មោះ [redacted] រ៉ូនី អត់ធ្លាប់ ឈ្មោះ [redacted] ពៅ ធ្លាប់ ឈ្មោះ [redacted] ឈៀវ អត់ទេ នៅផ្ទះសំណាក់ ឈ្មោះ [redacted] សុបញ្ញា អត់ដឹង ឈ្មោះ [redacted] រដ្ឋា អត់ដឹង ឈ្មោះ [redacted] សុវិជ្ជា ធ្លាប់ ឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] សីហា ដេកផ្ទះសំណាក់។ ក្រុមអត់ឈ្មោះទេ លឺគេថាឈ្មោះ សាមកុក ឈ្មោះ [redacted] ហេងរដ្ឋា ជាអ្នកដឹកនាំក្រុម។ អ្នក


Scanned with CamScanner

នៅផ្ទះសំណាក់មានឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] វ៉ូនី ឈ្មោះ [redacted] ឈៀវ និងឈ្មោះ ចាន់ ពេជ្រស្រីពីន ពួកគាត់អត់ធ្លាប់ទៅទេ នៅតែផ្ទះសំណាក់ ខ្លួនច្បាស់។ ពេលនៅផ្ទះសំណាក់ជាមួយពួកគាត់ៗ អត់ធ្លាប់ឆក់ទេ ស្រីៗនៅផ្ទះសំណាក់យូរហើយ ៣ ទៅ ៤ខែ ត្រូវជាសង្សារឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted] សីហា។ នៅផ្ទះសំណាក់អត់មានឧបករណ៍អីទេ។

ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនាថ ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវី តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនាថ ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-៧-ជនជាប់ចោទឈ្មោះ [redacted] ស្រីកុល៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនដឹងពីបទចោទខ្លួនហើយ សង្សារខ្លួនឈ្មោះ [redacted] សីហា។ ខ្លួនទៅផ្ទះសំណាក់លេងសម្រាកលេង បានចំនួន ០៦ថ្ងៃហើយ អ្នកជួលថ្លៃបន្ទប់គឺឈ្មោះ [redacted] ពេជ្រស្រីពីន ជួយចេញជាមួយខ្លួន។ ខ្លួនទើបស្គាល់សង្សារបានប្រហែល១០ថ្ងៃ បានទៅផ្ទះសំណាក់ដើម្បីសប្បាយ ខ្លួនអត់ដឹងថាអ្នកណាអ្នកឆក់ទេ ខ្លួនអត់បានចូលរួមក្រុមជាមួយពួកគេទេ ហើយខ្លួនអត់ដែលស្គាល់ពួកវាទេ។ ខ្លួនមិនបានយករបស់ពួកវាឆក់បានយកទៅលក់នោះទេ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានលុយចំនួន២៥ម៉ឺន ទូរស័ព្ទដៃមួយគ្រឿង គឺលុយបានមកពីខ្លួនធ្វើការខ្លួនចេញទៅក្រៅទៅរកលុយ ធ្វើការនៅការ៉ាអូខេនៅតាខ្មៅឈ្មោះ ពន្លឺ ពេជ្រ។

ជនជាប់ចោទឈ្មោះ [redacted] ស្រីកុល ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវី តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនាថ ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-៨-ជនជាប់ចោទឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនធ្លាប់ធ្វើសកម្មភាពឆក់ម្តង នៅផ្លូវអ្នកលឿងជាមួយឈ្មោះ [redacted] ហេងរដ្ឋា និងឈ្មោះ [redacted] ម៉ាណែត។ ឈ្មោះ [redacted] ហេងរដ្ឋា ឌុបឈ្មោះ [redacted] ម៉ាណែត ខ្លួនជិះម៉ូតូផ្សេង ម៉ូតូមានពីរគ្រឿង ឆក់បានចំនួនម្តង។ បានលុយហើយពួកវាអត់ដែលចែកឱ្យខ្លួនទេ ក្រុមមានគ្នាចំនួន១៥នាក់។

ជនជាប់ចោទឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយ



Scanned with CamScanner

របស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ា តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនាថ ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-៩-ជនជាប់ចោទឈ្មោះ [redacted] សុវិជ្ជា៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនបានដឹងបទចោទខ្លួនហើយ គ្នាខ្លួនមានចំនួន១៥នាក់ ស្រីៗពីរអ្នកនៅផ្ទះសំណាក់ជាមួយខ្លួន ខ្លួននៅជាមួយឈ្មោះ [redacted] ពេជ្រស្រីពីន ហើយឈ្មោះ [redacted] ពេជ្រស្រីពីន ដេកជាមួយខ្លួនមួយយប់។ ពេលចេញរកលុយធ្វើសកម្មភាពយប់ឡើង ខ្លួនអត់ប្រាប់ឈ្មោះ [redacted] ពេជ្រស្រីពីន ទេ ខ្លួនបានលុយ៥ ដុល្លារអាមេរិក ឱ្យឈ្មោះ [redacted] ពេជ្រស្រីពីន ប្រាប់ថាម្តាយខ្លួនឱ្យ។ ឆក់បានប្រាំមួយដងនៅកៀនស្វាយ មានគ្នា៦នាក់ធ្វើសកម្មភាពពេលដេកផ្ទះសំណាក់។ ឈ្មោះ [redacted] ពេជ្រស្រីពីន និងឈ្មោះ [redacted] ស្រីកុល និងពួកខ្លួនធ្វើសកម្មភាពឆក់មុនពេលប៉ូលីសចាប់ខ្លួនបានមួយថ្ងៃ។ ពេលចេញធ្វើសកម្មភាពដំបូងខ្លួននៅផ្ទះសំណាក់ ពេលចេញពីផ្ទះសំណាក់ខ្លួនទៅឆក់កាបូប ខ្លួនចេះបែកគំនិតឆក់តាមឈ្មោះ [redacted] ហេងរដ្ឋា និងឈ្មោះ [redacted] ម៉ាណែត ធ្វើរាង២ខ្លួន ពេលខ្លះធ្វើដោយឡែក។ លុយនឹងឥវ៉ាន់ឆក់បានចែកគ្នាអស់ហើយ។ អត់ដែលឆក់បានលុយច្រើនទេ អស់ត្រឹម១០០០ (មួយពាន់)ដុល្លារអាមេរិក ចែកគ្នាបានម្នាក់ ១០០ ទៅ២០០ ដុល្លារអាមេរិក លុយសល់ទុកចាយរួមគ្នាទាំង១០នាក់ជាង ផ្ទះសំណាក់ពីរបន្ទប់ ទុកចំណាយផ្ទះសំណាក់ បាយទឹក ដើរលេង។ ពេលឆក់គឺជិះអែបកៀនឆក់យក អត់ដែលស្រែកគំរាមទេ ពេលឆក់បានដាច់ខ្សែកាបូប ពេលខ្លះអត់ដាច់។ ពេលឆក់បានគ្រឿងអាលង្ការឈ្មោះ [redacted] ពៅ ជាអ្នកយកទៅលក់ ឥវ៉ាន់ឆក់បានគឺឈ្មោះ [redacted] ម៉ាណែត ជាអ្នករក្សាទុក និងអ្នកចែកមេចំណែកមានទាំងអស់គ្នា។

ជនជាប់ចោទឈ្មោះ [redacted] សុវិជ្ជា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ា តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុវិជ្ជា ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-១០-ជនជាប់ចោទឈ្មោះ [redacted] ហេងរដ្ឋា៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនអាយុ១៥ឆ្នាំ កើតអត់ចាំ រៀនថ្នាក់ទី៧។ ខ្លួនអត់ជាបងធំទេ។ ឈ្មោះ [redacted] ម៉ាណែត ជាបងធំ គាត់អ្នករៀបចំពេលធ្វើសកម្មភាពម្តងៗ ខ្លួនចូលរួមធ្វើជាមួយគាត់ដែរ ពេលបានលុយគាត់អ្នកចែកអ្នកទុក។ ខ្លួនធ្វើបានពីរដង ប៉ូលីសវ៉ាយឱ្យខ្លួនឆ្លើយ។ ក្រុមបង្កើតឆ្នាំ២០២១ ដើរលេង ចេញឆក់បានពីរដង ពេលឆក់បានឈ្មោះ [redacted] ម៉ាណែត កាន់កាប់និងយកទូរស័ព្ទទៅលក់។ ឈ្មោះ [redacted] ម៉ាណែត មេក្រុម សហការគ្នា គាត់អ្នកចេញលុយផ្ទះសំណាក់ ខ្លួនអត់មានដែលចេញទេ ព្រោះអត់សូវដែលបាននៅជាមួយ។ ក្រុមសាមកុក មានគ្នា១៥នាក់ ស្រីៗ ពីរនាក់ អត់សូវស្គាល់ អ្នកផ្សេង មាន ឈ្មោះ [redacted] ម៉ា ធ្លាប់ចូលរួម។ ខ្លួនអត់ទទួលស្គាល់ជាមេក្រុមទេឈ្មោះ



Scanned with CamScanner

[redacted] ម៉ាំណែត អ្នកហៅខ្លួនឆក់ ខ្លួនដែលបបួលឆក់ម្ដង ឆក់បានពីរដងបានប្រាក់១០ម៉ឺនរៀលនៅអ្នកឈឿងឈ្មោះ [redacted] ម៉ាំណែត អ្នកទុកនិងចែក អត់ដែលធ្វើមេចំណែកទេ។

ជនជាប់ចោទឈ្មោះ [redacted] ហេងរដ្ឋា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ី តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហេងរដ្ឋា ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-១១-ជនជាប់ចោទឈ្មោះ [redacted] ម៉ាំណែត៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនអត់បានរៀបគំរោងទេ គឺឈ្មោះ [redacted] ហេងរដ្ឋា។ ខ្លួនដឹងបទចោទប្រកាន់គឺពីបទឆក់។ ខ្លួនធ្លាប់ធ្វើសកម្មភាព៤ដង ក្រុមខ្លួនស្គាល់៤នាក់ ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] ៣៧ ឈ្មោះ [redacted] វឌ្ឍនាថ ព្រោះឧស្សាហ៍ចេញធ្វើសកម្មភាព ឈ្មោះ [redacted] ហេងរដ្ឋា អ្នកហៅ។ គាត់បបួលចេញយប់ម្ដង ពួកហែងចេញរកលុយជាមួយអញអត់តាម Chat ក្រុមគ្នាបួននាក់ អត់ឈ្មោះ អត់មានមេក្រុមសាមកុក អ្នកផ្សេងអត់ដឹងដែរ ឈ្មោះ [redacted] ម៉ា ទើបស្គាល់ក្នុងគុកនិយាយស្រែកឆ្លងឆ្លើយគ្នា។ ខ្លួនអត់បានទៅជាមួយឈ្មោះ [redacted] ឈៀវ ទេ។ ខ្លួនស្គាល់តែបួននាក់ហ្នឹងទេ ផ្ទះសំណាក់ច្បារអំពៅបើកជួលលបន្ទប់ គ្នាប្រហែល០៦ នាក់ ពីរនាក់ទៀតអត់ស្គាល់ ខ្លួនរៃលុយគ្នាបើកតែបន្ទប់។ ឈ្មោះ [redacted] ហេងរដ្ឋា ជាអ្នកចែក សំភារៈឆក់បាននៅឈ្មោះ [redacted] ហេងរដ្ឋា ព្រោះខ្លួនអ្នកដឹងម៉ាប់អ្នកឆក់ គាត់ទុករបស់ ខ្លួនអ្នកចែកតែលុយទេ។ របស់ឆក់បានខ្លួនធ្លាប់ទុកដែរ ឈ្មោះ [redacted] ហេងរដ្ឋា ជាបងធំ អត់មានបងទីពីរទេ។ ក្រុមខ្លួនមានគ្នា៤ នាក់ព្រោះធ្វើសកម្មភាពតែ៤នាក់ ហើយអ្នកផ្សេងគាត់ស្គាល់ខ្លួនតាមហ្វេសប៊ុកធ្វើសកម្មភាពពីរដង ដំបូងខ្លួនបិទគូទ ក្រោយមកធ្វើសកម្មភាពនៅផ្លូវជាតិលេខ៣ បានប្រាក់ចំនួន៣០ម៉ឺន ទូរស័ព្ទនិងចុងក្រោយនៅផ្លូវជាតិលេខ១។ មុខធ្វើសកម្មភាពអត់មានពិភាក្សាគ្នាទេ គឺពេលយប់ឧស្សាហ៍ជិះទៅអង្គុយលេងភ្នំពេញ មកវិញហូបអីឆក់តែម្ដង។ ឈ្មោះ [redacted] ហេងរដ្ឋា ជាអ្នកចាត់តាំង។ ក្រុមខ្លួនមាន០៤នាក់ ចេញឆក់សកម្មភាព ០៤ នាក់។ ខ្លួនស្ដាយក្រោយ ដឹងខុស។ ខ្លួនអត់ដែលមានសរសេរសំបុត្រសុំទោសក្នុងគុក។ លុយសល់ពីចែកគ្នាយកទៅហូបអី ចេញឱ្យថ្លៃផ្ទះសំណាក់។ ឈ្មោះ [redacted] ស្រីពីន ឈ្មោះ [redacted] ស្រីគុល ឈ្មោះ [redacted] វ៉ូនី ឈ្មោះ [redacted] បញ្ញា ឈ្មោះ [redacted] សីហា ក្រុមខ្លួនអត់មានឈ្មោះទេ។ សាមកុកខ្លួនឮគេល្បី ចេញបទចម្រៀងតាមតិកតុក។ អ្នកចេញលុយផ្ទះសំណាក់បានមកពីលុយឆក់រួមគ្នា។ ខ្លួនទើបស្គាល់១៤នាក់ទៀតក្នុងគុក។

ជនជាប់ចោទឈ្មោះ [redacted] ម៉ាំណែត ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ី តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ា



Scanned with CamScanner

ណែត ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-១២-ជនជាប់ចោទឈ្មោះ [redacted] ឈៀវ៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនដឹងបទឆក់ ខ្លួនឆក់បានបីដងជាមួយឈ្មោះ [redacted] សុបញ្ញា ឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] ម៉ាណែត។ ទីមួយជិតស្ពានអ្នកលឿង ឆក់អត់បានសម្រេច ទីពីរនៅស្ពានអ្នកលឿងអត់សម្រេច ទីបីនៅស្ពាងបាន៣ក់កណ្ដាលផ្លូវមកវិញ អត់បានអីទេ លើកទីបីបានត្រឡប់មក ព្រោះមេគេមក។ ឈ្មោះ [redacted] ម៉ាណែត និងឈ្មោះ [redacted] ហេងវដ្ឋា អ្នកឆក់ ខ្លួនដឹកឈ្មោះ [redacted] សុបញ្ញា បិទគូថ ខ្លួនអត់ដែលឆក់ជាមួយឈ្មោះ [redacted] ម៉ា ទេ។ ខ្លួនងងុយដេកទៅ៣ក់កណ្ដាលផ្លូវហើយមកវិញ។ ខ្លួនចាំចម្លើយនៅប៉ូលីសខ្លួនឆ្លើយថាឆក់បានបីលើក។ អ្នកឆក់មេឃ្លោង គឺឈ្មោះ [redacted] ម៉ាណែត និងឈ្មោះ វ៉ែន ហេងវដ្ឋាន ខ្លួនដេកផ្ទះសំណាក់ពីរកន្លែង។ អ្នកឆក់ឈ្មោះ [redacted] វដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] រ៉ូនី ឈ្មោះ [redacted] សីហា។ ស្រីៗ អត់ដឹងធ្វើអីទេ ឃើញតែនៅផ្ទះសំណាក់ ឈ្មោះ [redacted] ស្រីកុល ជាសង្សារឈ្មោះ [redacted] សីហា ឈ្មោះ [redacted] ពេជ្រស្រីពីន សង្សារ ឈ្មោះ [redacted] សុវិជ្ជា។ ឥវ៉ាន់មានតែឈ្មោះ [redacted] ហេង វដ្ឋា និង [redacted] ម៉ាណែត យកទៅលក់។ តុលាការអត់មានសំឡុតគំរាមកំហែងខ្លួនទេពេលសួរចម្លើយ។ ខ្លួនទទួលស្គាល់ចម្លើយនៅប៉ូលីស។ អ្នកចេញឆក់ ខ្លួនស្គាល់តែប៉ុន្មាននាក់ទេ ខ្លួនដឹងតែប៉ុន្មានអ្នកដែលធ្វើសកម្មភាពជាមួយខ្លួន។ ឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ [redacted] រ៉ូនី និងឈ្មោះ [redacted] ស្រីកុល អត់ដែលធ្វើសកម្មភាពទេ នៅតែផ្ទះសំណាក់។ ខ្លួនដឹង១២នាក់ទៀតធ្វើសកម្មភាពតាមរយៈមេក្រុមឈ្មោះ [redacted] ហេងវដ្ឋា ក្រុមឈ្មោះ [redacted] កុក ខ្លួនដឹងថាគឺជាក្រុមឆក់។ ផលបានពីការឆក់បានតែលើអ្នកចេញឆក់ទេ។ ចំពោះបាយអ្នកចេញឆក់ទិញឱ្យហូប ថ្លៃផ្ទះសំណាក់ឈ្មោះ [redacted] ម៉ាណែត ជាអ្នកចេញ។ បីនាក់ដេកផ្ទះសំណាក់អត់ចេញធ្វើសកម្មភាពទេ ចាំគេទិញបាយឱ្យហូប។ អត់ដែលដើរលេងជុំគ្នាអីទេ។ ខ្លួនអាយុ១៧ ឆ្នាំ កើតខែពីរ អត់ដឹងថ្ងៃ។ ឃើញឈ្មោះ [redacted] ហេងវដ្ឋា មាឌធំជាងខ្លួន។ ពេលជិះដល់កន្លែងឆក់តែម្ដង។ ឈ្មោះ [redacted] ហេងវដ្ឋា អ្នកកាន់លុយ។

ជនជាប់ចោទឈ្មោះ [redacted] ឈៀវ ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ី តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឈៀវ ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-១៣-ជនជាប់ចោទឈ្មោះ [redacted] វិសាល៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនធ្លាប់ធ្វើសកម្មភាពបីដង អត់ចាំជាមួយអ្នកណាទេខ្លួនធ្វើជាមួយឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted] ពៅ។ ក្រុមមាន ១៥ នាក់ ឈ្មោះ [redacted] ហេងវដ្ឋា ជាបងធំ។ ឆក់លើកទីមួយអត់ចាំឆក់បានអីខ្លះទេ យូរដែរ លើកទីពីរនៅស្ពាង បានប្រាក់អត់ចាំ ទីបីនៅផ្លូវជាតិលេខ៣ បានលុយ ៣០ម៉ឺនរៀល ទូរស័ព្ទពីរគ្រឿង យកទៅលក់ ឈ្មោះ [redacted] ម៉ាណែត អ្នកលក់។ ស្រីៗ មិនមែនអ្នកលក់ទេ ស្រីៗដេកផ្ទះ



Scanned with CamScanner

សំណាក់មកលេង អត់ស្គាល់ឈ្មោះ [redacted] រ៉ូនី ទេ អត់ដឹងបានលុយឆក់មកឱ្យពួកគាត់ទិញបាយទេ។ ស្រីៗ មិនមែនជាសង្សាខ្លួនទេ អត់សូវស្គាល់ស្រីៗទេ។ ទៅគ្នា៦នាក់ ទៅ៥នាក់ ខ្លួនអត់បានធាក់ម៉ូតូជនរងគ្រោះទេ។ខ្លួនទទួលស្គាល់កំណត់ហេតុនេះ ត្រូវហើយចម្លើយហ្នឹង ខ្លួនឈប់ធ្វើអញ្ចឹងទៀតហើយ ចម្លើយនេះជាការពិត។ ក្រុមមានគ្នាអត់ចាំច្រើននាក់ ១៥ នាក់ មានអ្នកខ្លះឆក់ខ្លះអត់មានឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រ៉ូនី និង ស្រីៗ ពីរនាក់ទៀត ច្បាស់ទៅឆក់ពេលខ្លះ៥នាក់ ពេលខ្លះ ៦នាក់ ខ្លួនច្បាស់តែអ្នកធ្លាប់ទៅឆក់ជាមួយ អ្នកអត់ធ្លាប់ជាមួយខ្លួនអត់ច្បាស់ទេ។

ជនជាប់ចោទឈ្មោះ [redacted] វិសាល ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ិ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-១៤-ជនជាប់ចោទឈ្មោះ [redacted] សីហា៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា សង្សាខ្លួនឈ្មោះ ឡាច ស្រីកុល ម្នាក់ទៀតសង្សាររបស់ឈ្មោះ [redacted] សុវិជ្ជា។ ខ្លួនអត់ដែលធ្លាប់ធ្វើសកម្មភាពទេ អត់ដែលទៅជាមួយគេផង។ ខ្លួនទៅនៅផ្ទះសំណាក់ផ្សេងគ្នា ឈ្មោះ [redacted] ហេងរដ្ឋា ជាបងធំ ក្រុមអត់មានឈ្មោះទេ ឈ្មោះ [redacted] រ៉ូនី ស្គាល់អត់ដែលចេញឆក់ទេ។ ពេលដេកផ្ទះសំណាក់ឈ្មោះ [redacted] ស្រីកុល ចេញលុយជួលកាលខ្លួនចេញលុយ ទិញបាយហូបដែរ សង្សាខ្លួនចេញពីផ្ទះ លុយគេសុំម៉ាក់ប៉ាចាយ អត់បានរួមភេទជាមួយសង្សាខ្លួនទេ ទើបទៅបានប៉ុន្មានថ្ងៃ។ ខ្លួនស្គាល់ឈ្មោះ [redacted] រ៉ូនី ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] ពេជ្រស្រីពីន និងឈ្មោះ [redacted] ហេងរដ្ឋា។ នៅផ្ទះសំណាក់ផ្សេងគ្នា ខ្លួននៅតាខ្មៅ ពួកហ្នឹងនៅច្បារអំពៅ។ ស្គាល់ស្រីៗ តាមឆាត អ្នកផ្សេងស្គាល់តាមមិត្តភក្តិឈ្មោះ [redacted] ម៉ា។ ខ្លួនទទួលស្គាល់ឈ្មោះ [redacted] ហេងរដ្ឋា ជាមេក្រុម ព្រោះឮគេថាគាត់បបួលគេទៅឆក់ គាត់ធំជាងគេ។ ខ្លួនអត់ទទួលស្គាល់គាត់ជាមេទេ [redacted] ហេងរដ្ឋា ទើបស្គាល់ពេលគេចាប់មក។ ខ្លួនចូលក្នុងក្រុមជាមួយឈ្មោះ [redacted] ហេងរដ្ឋា តែគ្រាន់តែ ដើរលេងអត់ដែលធ្វើសកម្មភាពទេ ទៅអង្គុយលេងវត្តភ្នំ កោះពេជ្រ។ ខ្លួនបានក្នុងហេតុការណ៍ហ្នឹងដែរ តែខ្លួនអត់បានឆក់ទេ។ លុយបាយទឹក និងដេកបានមកពីការឆក់ បាយទឹកឈ្មោះ [redacted] រ៉ូនី ពួកគាត់ទៅទិញខាងក្រៅ។ គ្នាខ្លួនជួយបួនបន្ទាប់ ទិញដាក់តាមបន្ទាប់រៀងខ្លួន។ ចូលក្រុមអត់មានលក្ខខណ្ឌទេ អត់ដឹងឈ្មោះក្រុមទេ រកម៉ាប់ដើរជាមួយអាសាមកុក នៅព្រែកឯង។ ខ្លួនទើបស្រឡាញ់គ្នាបានមួយអាទិត្យ អត់ដឹង [redacted] ស្រីកុល ធ្វើអីទេ។ ខ្លួនជាងកាត់សក់បើកនៅកៀនស្វាយ។

ជនជាប់ចោទឈ្មោះ [redacted] សីហា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សីហា ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៣-១៥-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ហៅ ជា៖ យោងតាមចម្លើយជនជាប់ចោទផ្ទាល់ ដែលបានឆ្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលថា ខ្លួនដឹងបទចោទហើយ ខ្លួនធ្លាប់ជិះក្រោយគេម្តង។ ឈ្មោះ [redacted] ម៉ា អ្នកហៅទៅ



Scanned with CamScanner

ឆក់នៅផ្លូវជាតិលេខ ៣ បីម៉ូតូ ដើម្បីធ្វើសកម្មភាព។ ខ្លួនស្គាល់តែឈ្មោះ [redacted]ម៉ា មួយ បានកន្លះខែ អត់ស្គាល់មេក្រុមទេឈ្មោះ [redacted]ម៉ា នៅជិះផ្ទះខ្លួន។ ខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted]ម៉ា អត់ដឹងសម្រេចទេ ខ្លួនត្រឡប់មកផ្ទះវិញ គាត់បបួលខ្លួនជិះដើរលេង ក៏ធ្វើសកម្មភាព ខ្លួនក៏ត្រឡប់មកផ្ទះវិញ ខ្លួនយកម៉ូតូត្រឡប់មកផ្ទះវិញ។ ក្រុមមានគ្នា ១៣ នាក់ ខ្លួនស្គាល់តែឈ្មោះ [redacted] សីហា និងឈ្មោះ[redacted]ម៉ា អត់ដឹងពួកវាដេកនៅណាទេ ខ្លួនដេកនៅផ្ទះ សមត្ថកិច្ចមកឃាត់ខ្លួននៅផ្ទះ។ អត់ដែលឆក់ជាមួយគេទេ អត់ដែលដើរជាមួយ១៣នាក់ ហ្នឹងទេ ខ្លួនទើបស្គាល់ពេលជាប់គុកជាមួយគ្នា។ ខ្លួនអត់ស្គាល់ឈ្មោះ[redacted]ហេងរដ្ឋា ទេ ខ្លួនស្គាល់ឈ្មោះ[redacted]ហេងរដ្ឋា ជាបងមិនមែនមេធំទេ។ បីម៉ូតូមានឈ្មោះ [redacted]ម៉ា ឈ្មោះ [redacted] ហេងរដ្ឋា ម្នាក់ទៀតអត់ស្គាល់ទេ ខ្លួនបានចូលរួមឆក់មែន លើកទីពីរឆក់អត់បានទេត្រឡប់មកវិញ។ ខ្លួនស្តាយក្រោយ ដឹងកំហុស។ ខ្លួនជិះម៉ូតូក្រោយបិទគូថ។ ក្រុមខ្លួន មាន៨នាក់ អត់ខ្លះចេញឆក់ខ្លះ។ អ្នកផ្សេងទៀតអត់ដឹងទេ។

ជនជាប់ចោទឈ្មោះ [redacted]រដ្ឋា ហៅ ជា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ ២០២១។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]ស្រីមុំ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បូលីន តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted] ស្រីល័ក្ខ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ជីវ៉ុ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថា តាមការពិនិត្យភស្តុតាងជាឯកសារនានាដែលមាននៅក្នុងសំណុំរឿង តុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ[redacted] រដ្ឋា ហៅ ជា ដែលមាននៅក្នុងអង្គហេតុខាងលើនេះគឺពិតជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រាកដមែន។

៤-យោងចំណុចទី ៣ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ ឃើញថា បច្ច័យទាំងនេះគឺកើតចេញពីអំពើរបស់ជនជាប់ចោទដោយផ្ទាល់ ដែលតម្រូវឱ្យជនជាប់ចោទទាំងអស់ទទួលខុសត្រូវចំពោះ អំពើល្មើសរបស់ខ្លួន។

៥-ធាតុអត្តនោម័តរបស់ជនជាប់ចោទ

៥-១-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋាៈ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានចូលរួមធ្វើសកម្មភាពឆក់ដោយខ្លួនជាអ្នកបិទគូថ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះជាច្រើនដង។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-២-ជនជាប់ចោទឈ្មោះ [redacted] ពៅៈ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានចូលរួមធ្វើសកម្មភាពឆក់ដោយខ្លួនជាអ្នកជិះម៉ូតូបិទគូទ បីនាក់ក្រោយអ្នកឆក់ បានសម្រេចចែកលុយគ្នា ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពី ចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះជាច្រើនដង។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៣-ជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ហៅ ចនៈ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈៀវ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទពិត

ជាបានចូលរួមនៅក្នុងក្រុមឆក់ ដោយបានស្នាក់នៅផ្ទះសំណាក់ និងហូបបាយទឹកដែលបានមកពីការឆក់ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការចូលរួមទៀត ។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៤-ជនជាប់ចោទឈ្មោះ [redacted] ពេជ្រស្រីពីន ៖ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវិជ្ជា តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទពិតជាបានចូលរួមនៅក្នុងក្រុមឆក់ ដោយបានស្នាក់នៅផ្ទះសំណាក់ និងហូបបាយទឹកដែលបានមកពីការឆក់ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការចូលរួមទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៥-ជនជាប់ចោទឈ្មោះ [redacted] ម៉ា ហៅ ឡា៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានធ្វើសកម្មភាពជាអ្នកបិទគូថឱ្យគេជាអ្នកឆក់ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះ ទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៦-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនាថ៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ ជាអ្នកជិះបិទគូថ ឱ្យឈ្មោះ [redacted] ហេងវដ្ឋា និងឈ្មោះ [redacted] ម៉ាណែត ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៧-ជនជាប់ចោទឈ្មោះ [redacted] ស្រីកុល៖ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវិជ្ជា តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទពិតជាបានចូលរួមនៅក្នុងក្រុមឆក់ ដោយបានស្នាក់នៅផ្ទះសំណាក់ និងហូបបាយទឹកដែលបានមកពីការឆក់ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៨-ជនជាប់ចោទឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ ខ្លួនធ្លាប់ធ្វើសកម្មភាពឆក់ម្តង នៅផ្លូវអ្នកលឿង ជាមួយឈ្មោះ [redacted] ហេងវដ្ឋា ឈ្មោះ [redacted] ម៉ាណែត ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀត។



Scanned with CamScanner

សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-៩-ជនជាប់ចោទឈ្មោះ [redacted] សុវិជ្ជា៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានធ្វើសកម្មភាពឆក់ គឺពេលឆក់ជាច្រើនដងពេលចេញពីផ្ទះសំណាក់ ពេលឆក់ជិះអែបគៀនឆក់យក ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀតជាច្រើនដង។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-១០-ជនជាប់ចោទឈ្មោះ [redacted] ហេងរដ្ឋា៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានធ្វើសកម្មភាពបបួលគេទៅឆក់ និងបានឆក់គេជាច្រើនដង ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះជាច្រើនដង។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-១១-ជនជាប់ចោទឈ្មោះ [redacted] ម៉ាណែត៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ ខ្លួនធ្លាប់ធ្វើធ្វើសកម្មភាពនៅផ្លូវជាតិលេខ៣ បានប្រាក់ចំនួន៣០ម៉ឺន ទូរស័ព្ទលើកទីបួន នៅផ្លូវជាតិលេខ១ និងចុងក្រោយនៅផ្លូវជាតិលេខ១ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះជារឿយៗ។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-១២-ជនជាប់ចោទឈ្មោះ [redacted] ឈៀវ៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានធ្វើសកម្មភាពឆក់បានបីដងជាមួយឈ្មោះ [redacted] សុបញ្ញា វ៉េន ឈ្មោះ [redacted] រដ្ឋា ឈ្មោះ [redacted] ម៉ាណែត ទីមួយជិតស្ពានអ្នកលឿង ឆក់អត់បានសម្រេច ទីពីរនៅស្ពានអ្នកលឿងអត់សម្រេច ទីបីនៅស្ពាង ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-១៣-ជនជាប់ចោទឈ្មោះ [redacted] វិសាល៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានធ្វើសកម្មភាពឆក់បីដង អត់ចាំជាមួយអ្នកណាទេខ្លួនធ្វើជាមួយឈ្មោះ [redacted] ហេងរដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted] ពៅ ទីមួយអត់ចាំឆក់បានអីខ្លះទេ យូរដែរ លើកទីពីរនៅស្ពាង បានប្រាក់អត់ចាំ ទីបីនៅផ្លូវជាតិលេខ៣ បានលុយ ៣០ម៉ឺនរៀល ទូរស័ព្ទពីរគ្រឿង ហើយជនជាប់



Scanned with CamScanner

ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-១៤-ជនជាប់ចោទឈ្មោះ [redacted] សីហា៖ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈៀវ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទពិតជាបានចូលរួមនៅក្នុងក្រុមឆក់ ដោយបានស្នាក់នៅផ្ទះសំណាក់ និងហូបបាយទឹកដែលបានមកពីការឆក់ ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការចូលរួមទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-១៥-ជនជាប់ចោទឈ្មោះ[redacted]រដ្ឋា ហៅ ជា៖ តាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ តាមចម្លើយរបស់ជនរងគ្រោះ តាមចម្លើយរបស់សាក្សី និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថាជនជាប់ចោទផ្ទាល់ បានធ្វើសកម្មភាពឆ្លាប់ជិះក្រោយគេម្តងដោយឈ្មោះ[redacted]ម៉ា អ្នកហៅទៅឆក់ផ្លូវជាតិលេខ ៣ បីម៉ឺតូ ដើម្បីធ្វើសកម្មភាព ហើយជនជាប់ចោទផ្ទាល់មានការយល់ដឹងយ៉ាងច្បាស់ពីចរឹកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ប៉ុន្តែខ្លួននៅតែមានឆន្ទៈ និងបន្តការប្រព្រឹត្តអំពើនេះទៀត។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពីកម្រិតនៃការយល់ដឹង និង ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ[redacted]រដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted]វ៉ូនី ហៅ ចន ឈ្មោះ[redacted]ពេជ្រស្រីពីន ឈ្មោះ[redacted]ម៉ា ហៅ ឡា ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted]ស្រីកុល ឈ្មោះ[redacted]សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ[redacted] ហេងរដ្ឋា ឈ្មោះ[redacted]ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ[redacted]វិសាល ជាអំពើមួយដែលធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិបុគ្គល សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គម ជាអំពើមួយដែល ច្បាប់បញ្ញត្តិចែងថា ជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ឯឈ្មោះ [redacted] សីហា ឈ្មោះ [redacted]រដ្ឋា ហៅ ជា ជាអំពើមួយដែលធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិបុគ្គល សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គម ប៉ះពាល់ដល់បូរណៈភាពបុគ្គល ជាអំពើមួយដែល ច្បាប់បញ្ញត្តិចែងថា ជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចធ្វើការប្រកាសទោសឱ្យជនជាប់ចោទទទួលខុសត្រូវតាមបញ្ញត្តិមាត្រាខាងលើ។

៧-មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វ៉ូនី ហៅ ចន ឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ[redacted]ម៉ា ហៅ ឡា ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] សុវិជ្ជា ឈ្មោះ[redacted]ហេងរដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ[redacted] វិសាល ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្ត

អំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ឯឈ្មោះ [redacted]សីហា ឈ្មោះ [redacted]ដ្ឋា ហៅ ជា ពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-អយ្យការធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោល រឿងនេះដំបូងជនជាប់ចោទច្រើនដោយសារតែចុងក្រោយជនជាប់ចោទទាំង១៥ នាក់ រកឃើញថាជនជាប់ចោទទាំង១៥ នាក់ ជាក្រុមឧក្រិដ្ឋជនវ័យក្មេងមានមេក្រុមមានចាត់តាំង មានទីតាំងប្រព្រឹត្តស្នាក់នៅលាក់ខ្លួន ហើយទ្រព្យបានពីប្រព្រឹត្តយកមក ទីកន្លែងផ្ទះសំណាក់ថ្ងៃដើរលេងហូបចុកប្រចាំថ្ងៃ មានមេឃ្លោងសកម្មពីរនាក់ គឺឈ្មោះ [redacted]ហេងរដ្ឋា និងឈ្មោះ [redacted] ម៉ាណែត។ ក្នុងការបង្កើតក្រុមជនជាប់ចោទទាំងនេះបានប្រព្រឹត្តបទល្មើស បង្កភាពវឹកវរ ចលាចលក្នុងសង្គមបណ្តាលឱ្យជនរងគ្រោះបាត់ទ្រព្យសម្បត្តិរាប់ពាន់ដុល្លារ។ សកម្មភាពដែលជនជាប់ចោទបានប្រព្រឹត្តជាបទឆក់នៅទីសាធារណៈដោយប្រើហិង្សាកម្លាំងបង្ខំ ដើម្បីសម្រេចបទល្មើស ជាបទល្មើសលួចមានស្ថានទម្ងន់ទោសប្រើហិង្សា យោងតាមមាត្រា ៣៥៣ និង៣៦៧ នៃក្រមព្រហ្មទណ្ឌ។ ក្នុងចំនោម១៥នាក់ មានតែ៤នាក់ដែលមិនមានសកម្មភាពផ្ទាល់ តែបានរួមក្រុមទទួលផលនិងសម្រួលពីអំពើឆក់នេះ ដូចជាឈ្មោះ [redacted] ស្រីពីន បានសារភាពបានចូលក្រុមហ្នឹងបញ្ជូនម៉ូតូឱ្យឈ្មោះនេះជិះធ្វើសកម្មភាពឆក់។ ត្បិតថាជនជាប់ចោទ បីនាក់មានឈ្មោះ [redacted] ឈ្មោះ [redacted] ស្រីកុល និងឈ្មោះ [redacted] វ៉ូនី មិនបានចូលរួមធ្វើសកម្មភាពចេញឆក់ តែដឹងក្រុមបង្កើតដើម្បីអី ហើយចុងក្រោយឈ្មោះ [redacted] ពីន ដឹងចង់ចេញ តែអត់ទាន់ក៏ត្រូវប៉ូលីសចាប់។ សរុបសេចក្តីមកជនជាប់ចោទទាំង១៥ នាក់ ពិតបានប្រព្រឹត្ត ដូចការចោទប្រកាន់មែន ត្បិតជនជាប់ចោទអនីតិជនត្រូវទទួលបានបន្ធូរបន្ថយទោស តែបើពិនិត្យសកម្មភាព បង្កគ្រោះថ្នាក់ដល់សង្គម គប្បីត្រូវផ្តន្ទាទោសអតិបរមានៃទោស ដើម្បីជាការព្រមាន និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សូមឱ្យក្រុមប្រឹក្សាម្រេចផ្តន្ទាទោសជនជាប់ចោទទាំង ១៥នាក់ ពីបទលួចមានស្ថានទម្ងន់ទោស ដោយប្រើហិង្សាក្នុងអតិប្បរមាន លើកលែងជនជាប់ចោទឈ្មោះ [redacted] វ៉ូនី ឈ្មោះ [redacted]ពេជ្រស្រីពីន និងឈ្មោះ [redacted]ស្រីកុល មិនមានភាពសកម្មមិនបានប្រព្រឹត្តផ្ទាល់ សូមពិចារណាបន្ធូរបន្ថយទោសខ្លះ។

តំណាងអយ្យការប្តឹងសុំ៖ ឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]រដ្ឋា ឈ្មោះ [redacted]ពៅ ឈ្មោះ [redacted] វ៉ូនី ហៅ ចន ឈ្មោះ [redacted] ពេជ្រស្រីពីន ឈ្មោះ [redacted]ម៉ា ហៅ ឡា ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted]សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted]សុវិជ្ជា ឈ្មោះ [redacted]ហេងរដ្ឋា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted]ឈៀវ ឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted]សីហា ឈ្មោះ [redacted]រដ្ឋា ហៅ ជា តាមច្បាប់។ ចំពោះការប្តឹងសុំរបស់តំណាងអយ្យការលើចំណុចនេះ តុលាការបានយល់ឃើញដូចមាននោះក្នុងចំណុច ៣-១. ៣-២. ៣-៣- ៣-៣- ៣-៤. ៣-៥. ៣-៦. ៣-៧. ៣-៨. ៣-៩. ៣-១០. ៣-១១. ៣-១២. ៣-១៣- ៣-១៤. ៥-១. ៥-២. ៥-៣- ៥-៤. ៥-៥. ៥-៦. ៥-៧. ៥-៨. ៥-៩. ៥-១០. ៥-១១. ៥-១២. ៥-១៣- ៥-១៤. ៥-១៥. ៦. ៧ និងចំណុចទី១៤ នៃផ្នែកសំអាងហេតុ នៃសាលក្រមនេះ។



Scanned with CamScanner

៩-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពិភាក្សាដេញដោល ឃើញថាកូនក្តីខ្លួនចំនួនដប់នាក់ មានឈ្មោះ [redacted] រដ្ឋា ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] វឌ្ឍនាថ ឈ្មោះ [redacted] ស្រីកុល ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ឈ្មោះ [redacted] ម៉ាណែត ឈ្មោះ [redacted] ឈៀវ ឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រដ្ឋា ហៅ ជា បានទទួលស្គាល់កំហុសនូវអ្វីដែលខ្លួនបានធ្វើ ព្រោះចម្លើយទាំងអស់នេះនៅក្នុងសវនាការនេះក៏ដូចជានៅក្នុង ដំណាក់កាលស៊ើបសួរទាំងអស់ គឺមានលក្ខណៈស៊ីសង្វាក់គ្នា ខ្លួនសំណូមពរឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក៏ដូចជា ក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់ស្ថានសម្រាលទោសត្រឹមកម្រិតណាមួយនៃច្បាប់ ព្រោះពួកគាត់ទាំងអស់ ស្ថិតនៅជា អនីតិជន មួយទៀតគឺឈ្មោះ [redacted] ស្រីកុល បន្ទាប់ស្តាប់នៅក្នុងអង្គសវនាការ ជនជាប់ចោទទាំងអស់បានឆ្លើយថា បដិសេធហើយថាឈ្មោះ [redacted] ស្រីកុល នេះគឺគាត់មិនបានចូលរួមនៅក្នុងសកម្មភាពទាំងអស់នេះទេ ហើយបើយើង ពិនិត្យនៅក្នុងកំណត់ហេតុស៊ើបសួរទាំងអស់នៃជនជាប់ចោទផ្សេងៗទៀត ហើយក៏ដូចនៅក្នុងអង្គសវនាការនេះដែរ ឈ្មោះ [redacted] ស្រីកុល នេះគឺមិនមានពាក់ព័ន្ធនេះផងដែរ ជាចុងក្រោយស្នើសុំឱ្យឈ្មោះ [redacted] ស្រីកុល រួចផុតពីបទ ចោទ។

ចំពោះការប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ តុលាការបានយល់ឃើញដូចមាននោះក្នុងចំណុច ទី ៣-១. ៣-២. ៣-៦. ៣-៧. ៣-៨. ៣-១១. ៣-១២. ៣-១៣. ៣-១៤. ៣-១៥. ៥-១. ៥-២. ៥-៦. ៥-៧. ៥-៨. ៥-១១. ៥-១២. ៥-១៣. ៥-១៤. ៥-១៥. ៦. ៧. ៨.និងចំណុចទី១៤ នៃផ្នែកសំអាងហេតុ នៃសាលក្រមនេះ។

១០-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការពិភាក្សាដេញដោលឃើញថាឈ្មោះ [redacted] រដ្ឋា ឈ្មោះ [redacted] សុវិជ្ជា និងឈ្មោះ [redacted] បានសារភាព សូមតុលាការពិចារណាស្ថានសម្រាល។ ចំពោះឈ្មោះ [redacted] ពេជ្រស្រីពីន និងឈ្មោះ [redacted] វ៉ូនី ឆ្លងការពិភាក្សា គាត់បដិសេធការចោទប្រកាន់ ដោយសារគាត់មិនបានចូលរួម សកម្មភាពនឹងគេទេ ហើយចម្លើយរបស់ពួកគាត់តាំងពីនៅមន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយរបស់ជនជាប់ចោទ ផ្សេងស៊ីសង្វាក់គ្នា ពួកគាត់អត់បានចូលរួម ហើយចំពោះចម្លើយរបស់ឈ្មោះ ចាន់ ពេជ្រស្រីពីន ថាបានយកម៉ូតូឱ្យគេ ព្រោះមកពីសួរគាត់ច្រើនលើក បើពិនិត្យឃើញថាមិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទេសូមលើកលែង តែបើ ប្រធានក្រុមប្រឹក្សាឃើញថាមានភស្តុតាងដាក់បន្ទុក សូមផ្តល់ស្ថានសម្រាល ព្រោះគាត់មិនមែនជាជនសកម្មក្នុងក្រុម ដូចអយ្យការចោទទេ។

ចំពោះការប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ តុលាការបានយល់ឃើញដូចមាននោះក្នុងចំណុច ទី ៣-៣. ៣-៤. ៣-៥. ៣-៩. ៥-៣- ៥-៤. ៥-៥. ៥-៩. ៦. ៧. ៨. ១៣ និងចំណុចទី១៤ នៃផ្នែកសំអាងហេតុ នៃ សាលក្រមនេះ។

១១-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងកាត់តាមការពិភាក្សាពិនិត្យឃើញថា ការប្រព្រឹត្តបទល្មើស នេះ ចូលរួមជាមួយគ្នា គ្មានអ្នកបង្ខំនរណាទេ គ្រាន់តែចម្លើយឈ្មោះ [redacted] សុវិជ្ជា ថា ម្តងពាក់ព័ន្ធឈ្មោះ [redacted] ម៉ាណែត ម្តងថាឈ្មោះ [redacted] ហេងរដ្ឋា។ ចម្លើយនៅប៉ូលីសមានការបង្ខិតបង្ខំ ហើយកូនក្តីខ្លួនវ័យអនីតិជន ១៥ឆ្នាំ មានសំបុត្រកំណើតបញ្ជាក់ ចំណុចមួយទៀតទាក់ទងការបែងចែកផលប្រយោជន៍ គឺឈ្មោះ [redacted] ម៉ាណែត។ អញ្ចឹងឈ្មោះ [redacted] ហេងរដ្ឋា មិនមែនជាប្រធានក្រុមឆក់ផ្តាច់មុខ គឺធ្វើរួមគ្នា មួយទៀតអ្នកទាំងអស់គ្នាចូលរួមដោយស័



Scanned with CamScanner

គ្រូចិត្តទេ ហើយចែកចំណែកដោយពិភាក្សាគ្នា មិនមែនដាច់ខាត់ត្រូវកូនក្តីខ្លួនជាអ្នកកំណត់ទេ ហើយទាក់ទងម៉ូតូសូមប្រគល់ឱ្យម្តាយគាត់វិញ ព្រោះជារបស់ម្តាយគាត់។ អំពើរបស់ជនល្មើសមិនបានបង្កឱ្យមានរបួសស្នាមទេ ហើយជាតុអត្តនោម័ត គឺជនជាប់ចោទភ័យ។ មួយទៀតទាក់ទងការសម្រាលទោសក្នុងមាត្រាខ្លះ ការព្យួរ ការណែនាំ ចំពោះអនីតិជនក្រោម១៨ឆ្នាំ។ សូមស្ថានសម្រាលទោស អប្បរមាទោស និងសូមម៉ូតូប្រគល់ឱ្យម្តាយវិញ។

ចំពោះការប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ តុលាការបានយល់ឃើញដូចមាននោះក្នុងចំណុចទី ៣-១០. ៥-១០. ៦. ៧. ៨.និងចំណុចទី១៤ នៃផ្នែកសំអាងហេតុ នៃសាលក្រមនេះ។

១២-សំណូមពររបស់ជនជាប់ចោទៈ

១២-១ ជនជាប់ឈ្មោះ[redacted]រដ្ឋា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-២ ជនជាប់ឈ្មោះ[redacted]ពៅ សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-៣ ជនជាប់ឈ្មោះ [redacted] រ៉ូនី ហៅ ចន សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ដល់ខ្លួនផង។

១២-៤ ជនជាប់ឈ្មោះ [redacted] ពេជ្រស្រីពីន សំណូមពរសុំឱ្យតុលាការដោះលែងខ្លួនព្រោះខ្លួនពុំបានធ្វើសកម្មភាព។

១២-៥ ជនជាប់ឈ្មោះ [redacted]ម៉ា ហៅ ឡា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-៦ ជនជាប់ឈ្មោះ [redacted]វណ្ណនាថ សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-៧ ជនជាប់ឈ្មោះ [redacted]ស្រីកុល សំណូមពរសុំឱ្យតុលាការដោះលែងខ្លួនព្រោះខ្លួនពុំបានធ្វើសកម្មភាព។

១២-៨ ជនជាប់ឈ្មោះ[redacted]សុបញ្ញា ហៅ ញ៉ា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-៩ ជនជាប់ឈ្មោះ[redacted]សុវិជ្ជា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-១០ ជនជាប់ឈ្មោះ[redacted] ហេងរដ្ឋា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-១១ ជនជាប់ឈ្មោះ[redacted]ម៉ាណែត សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-១២ ជនជាប់ឈ្មោះ [redacted]ឈៀវ សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-១៣ ជនជាប់ឈ្មោះ [redacted]សោល សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-១៤ ជនជាប់ឈ្មោះ [redacted]សីហា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

១២-១៥ ជនជាប់ឈ្មោ[redacted]រដ្ឋា ហៅ ជា សំណូមពរសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

ចំពោះសំណូមពររបស់ជនជាប់ចោទទាំងអស់ តុលាការបានយល់ឃើញដូចមាននោះក្នុងចំណុចទី ៣-១. ៣-២. ៣-៣- ៣-៣- ៣-៤. ៣-៥. ៣-៦. ៣-៧. ៣-៨. ៣-៩. ៣-១០. ៣-១១. ៣-១២. ៣-១៣- ៣-១៤. ៥-១. ៥-២. ៥-៣- ៥-៤. ៥-៥. ៥-៦. ៥-៧. ៥-៨. ៥-៩. ៥-១០. ៥-១១. ៥-១២. ៥-១៣- ៥-១៤. ៥-១៥. ៦. ៧. ៨. ១៣ និងចំណុចទី១៤ នៃផ្នែកសំអាងហេតុ នៃសាលក្រមនេះ។



Scanned with CamScanner

១៣-យោងសំបុត្របញ្ជាក់កំណើតលេខ ២០៥៦ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៥ របស់មន្ត្រីអត្រានុកូលដ្ឋាន បញ្ជាក់ថាឈ្មោះ [redacted]ម៉ា ភេទប្រុស កើតថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៤។ ដូចនេះឈ្មោះ ធី ម៉ា ទើបតែមានអាយុ១៧ឆ្នាំ ជាងប៉ុណ្ណោះ។ គិតត្រឹមកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស។

១៤-តុលាការយល់ឃើញថា ជនជាប់ចោទទាំងអស់ជាអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំឡើង ដូចនេះ មូលទោសបទល្មើសដែលត្រូវចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌ អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល និងអប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី១ (មួយ) ថ្ងៃ យោងតាមមាត្រា១៦០ កថាខណ្ឌទី១ ចំណុច១ និងចំណុច៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ដែលចែងអំពីគោលការណ៍ជាមូលដ្ឋានដែលត្រូវគោរព ចំពោះការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចការផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន។

១៥-វត្ថុចាប់យករួមមាន

១៥-១-ម៉ូតូចំនួន០៨គ្រឿង៖

១៥-១-១-ម៉ូតូម៉ាក Honda dream c15 ពណ៌ក្រហម ផ្លាកលេខ កំពង់ធំ ១N-៦៦៧៤ (មិនប្រក្រតី)។ តាមពាក្យស្នើសុំ ម៉ូតូ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted]សុខាក់ និងប័ណ្ណសម្គាល់រថយន្ត ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ បញ្ជាក់ថា ម៉ូតូម៉ាក Honda dream c15 ពណ៌ក្រហម កំពង់ធំ ១N-៦៦៧៤ ពិតជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុខាក់ ភេទស្រី អាយុ ៤១ឆ្នាំ ដែលមានអាសយដ្ឋាន ភូមិវាល ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ប្រាកដមែន ហើយឈ្មោះ [redacted]សុខាក់ បានស្នើសុំម៉ូតូនេះវិញ ដោយសារម៉ូតូត្រូវក្មួយឈ្មោះ[redacted] ម៉ា ខ្ចីជិះ។ ហើយខ្លួនមានជីវភាពក្រីក្រ និងមិនមានអ្វីធ្វើដំណើរទៅធ្វើការ គប្បីតុលាការសម្រេចតាមពាក្យសុំ។

១៥-១-២-ម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១IT-៣០៧៧ (មិនប្រក្រតី)។ តាមពាក្យស្នើសុំម៉ូតូ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ[redacted] ស្រីពៅ និងប័ណ្ណសម្គាល់រថយន្តបញ្ជាក់ថាម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ភ្នំពេញ ១IT-៣០៧៧ ពិតជាកម្មសិទ្ធិរបស់ឈ្មោះ[redacted]ស្រីពៅ ដែលមានអាសយដ្ឋានផ្ទះលេខ ១៦៨ ផ្លូវលេខ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ពិតមែន ហើយឈ្មោះ[redacted] ស្រីពៅ បានស្នើសុំម៉ូតូនេះយកទៅវិញ ដោយសារជាម៉ូតូរបស់ខ្លួនដែលកូនយកជិះដើរលេង។ ខ្លួនមានជីវភាពក្រីក្រ មិនមានអ្វីធ្វើដំណើរទៅធ្វើការ ទើបខ្លួនសុំម៉ូតូយកមកប្រើប្រាស់វិញ គប្បីតុលាការសម្រេចតាមពាក្យសុំ។

១៥-១-៣-ម៉ូតូម៉ាក Honda Scoopy I ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១II -២០១៥ (មិនប្រក្រតី)។ តាមពាក្យស្នើសុំម៉ូតូ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ខៀវ និងប័ណ្ណសម្គាល់រថយន្ត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ បញ្ជាក់ថា ម៉ូតូម៉ាក Honda Scoopy I ពណ៌ខ្មៅ ភ្នំពេញ ១II -២០១៥ ពិតជាកម្មសិទ្ធិរបស់ឈ្មោះ[redacted]ខៀង ភេទស្រី អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ ដែលមានអាសយដ្ឋានផ្លូវលំ ភូមិទួល សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ពិតមែន ហើយឈ្មោះ[redacted]ខៀង បានស្នើសុំម៉ូតូនេះយកទៅប្រើប្រាស់វិញ ពីព្រោះជាម៉ូតូរបស់ខ្លួនដែលត្រូវកូនយកទៅជិះ។ ហើយខ្លួនមានជីវភាពខ្វះខាត់ ទើបខ្លួនសុំម៉ូតូនេះមកប្រើប្រាស់វិញ គប្បីតុលាការសម្រេចតាមពាក្យសុំ។



Scanned with CamScanner

១៥-១-៤-ម៉ូតូម៉ាក Honda Scoopy I ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១IN-៦៥២០ (មិនប្រក្រតី)។ តាមពាក្យស្នើសុំម៉ូតូ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ស្រីភ័ក្រ និងប័ណ្ណសម្គាល់រថយន្ត ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ បញ្ជាក់ថា ម៉ូតូម៉ាក Honda Scoopy I ពណ៌ខ្មៅ ភ្នំពេញ ១IN-៦៥២០ ពិតជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ស្រីភ័ក្រ ភេទស្រី កើតឆ្នាំ១៩៩០ ដែលមានអាសយដ្ឋានភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រាកដមែន ហើយឈ្មោះ [redacted] ស្រីភ័ក្រ បានស្នើសុំម៉ូតូនេះយកទៅប្រើប្រាស់វិញ ដោយសារតែម៉ូតូនេះជារបស់ខ្លួន ត្រូវក្តីឈ្មោះ [redacted] រដ្ឋា ខ្ទីជិះ។ ហើយខ្លួនមានជីវភាពក្រីក្រ និងមិនមានអ្វីធ្វើដំណើរទៅធ្វើការ គប្បីតុលាការសម្រេចតាមពាក្យសុំ។

១៥-១-៥-ម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ផ្លាកលេខ កណ្តាល ១Q -9099 (មិនប្រក្រតី) មិនមានឯកសារបញ្ជាក់អំពីកម្មសិទ្ធិច្បាស់លាស់ និងជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

១៥-១-៦-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ផ្លាកលេខ សៀមរាប ១X-៤៣៤៧ (មិនប្រក្រតី) មិនមានឯកសារបញ្ជាក់អំពីកម្មសិទ្ធិច្បាស់លាស់ និងជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

១៥-១-៧-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស ផ្លាកលេខ ភ្នំពេញ ១FH-៣០៧៣ (មិនប្រក្រតី) មិនមានឯកសារបញ្ជាក់អំពីកម្មសិទ្ធិច្បាស់លាស់ និងជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

១៥-១-៨-ម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១BQ -១៦៥១ (មិនប្រក្រតី) មិនមានឯកសារបញ្ជាក់អំពីកម្មសិទ្ធិច្បាស់លាស់ និងជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

១៥-២-ប័ណ្ណ ប.ស.ស ឈ្មោះ [redacted] ភាន់ លេខ 1981-1918312-ព គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៣-ប័ណ្ណ ប.ស.ស ឈ្មោះ [redacted] សារ៉េត លេខ 2830816-0200956-ទ គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៤-កាត់ Wing មាន០២ លេខគណនីវីង 03371901 និងមួយទៀត លេខគណនីវីង លេខ 03964833 គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៥-អត្តសញ្ញាណប័ណ្ណមាន០៣ ឈ្មោះ [redacted] សារ៉េត លេខ 050984717 ,ឈ្មោះ [redacted] ឈៀវ លេខ 011343992, ឈ្មោះ [redacted] សុបញ្ញា លេខ 011401421គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៦-ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ មានចំនួន០៥ (ឈ្មោះ [redacted] ហេងរដ្ឋា, ឈ្មោះ [redacted] សៀង, ឈ្មោះ [redacted] ស្រីស, ឡាច ស្រីកុល និងឈ្មោះ [redacted] សបញ្ញា) គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៧-កាតចេញចូលរោងចក្រ ឈ្មោះ [redacted] សារ៉េត SW50045 គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៨-លោហៈធាតុពណ៌លឿង (កងដៃ) ៦កង និងលោហៈធាតុពណ៌ទឹកប្រាក់ ០១កង និងចិញ្ចៀន០២វង់ និងមួយទៀតមានដាំត្បូងពណ៌ស ចំនួន១៩គ្រាប់ គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១៥-៩-កាបូបដៃស្រីចំនួន០៣ និងកាបូបដៃប្រុសចំនួន៤ និងកាបូបធំស្ពាយពីក្រោយចំនួន០១ គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។



Scanned with CamScanner

**ដោយសេចក្តីសម្រេចជាឯកច្ឆន្ទនៃក្រុមប្រឹក្សាជំនុំជម្រះ**

**ហេតុដូចនេះសាលាដំបូងខេត្តកណ្តាល**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

១-១-ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៦) ឈ្មោះ [redacted] រ៉ូនី ហៅ ចន ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៦) ឈ្មោះ [redacted] ពេជ្រស្រីពីន ភេទស្រី អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ឈ្មោះ [redacted] ម៉ា ហៅ ឡា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ឈ្មោះ [redacted] វឌ្ឍនាថ ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៥) ឈ្មោះ [redacted] ស្រីកុល ភេទស្រី (កើតឆ្នាំ២០០៤) ឈ្មោះ [redacted] សុវិជ្ជា ភេទប្រុស អាយុ១៥ឆ្នាំ ឈ្មោះ [redacted] ឈៀវ ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៥) ដែលមានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ ០៦ខែ ពីបទ៖អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១-២-ឈ្មោះ [redacted] សីហា ភេទប្រុស កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] រដ្ឋា ហៅ ជា ភេទប្រុស អាយុ១៥ឆ្នាំ ដែលមានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ ០៦ខែ ពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១-៣-ឈ្មោះ [redacted] សុបញ្ញា ហៅ ញ៉ា ភេទប្រុស អាយុ១៧ឆ្នាំ (កើតឆ្នាំ២០០៤) ដែលមានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ ពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១-៤-ឈ្មោះ [redacted] ហេងរដ្ឋា ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] ម៉ាណែត ភេទប្រុស អាយុ១៧ឆ្នាំ ដែលមានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ ពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុតាងមាន៖

២-១-ម៉ូតូចំនួន០៨គ្រឿង៖

២-១-១-ម៉ូតូម៉ាក Honda dream c15 ពណ៌ក្រហម ផ្លាកលេខ កំពង់ធំ ១N-៦៦៧៤ (មិនប្រក្រតី) ប្រគល់ឱ្យឈ្មោះ បាក់ សុខាក់ ភេទស្រី អាយុ ៤១ឆ្នាំ អាសយដ្ឋាន ភូមិវាល ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ។

២-១-២-ម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១IT-៣០៧៧ (មិនប្រក្រតី) ប្រគល់ឱ្យឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ ៣៩ឆ្នាំ អាសយដ្ឋានផ្ទះលេខ១៦៨ ផ្លូវលេខ៣៦៩ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



Scanned with CamScanner

២-១-៣-ម៉ូតូម៉ាក Honda Scoopy I ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១II -២០១៥ (មិនប្រក្រតី) ប្រគល់ឱ្យឈ្មោះ [redacted] ខៀង ភេទស្រី អាយុ ៤០ឆ្នាំ អាសយដ្ឋានផ្លូវលំ ភូមិទួល សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

២-១-៤-ម៉ូតូម៉ាក Honda Scoopy I ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១IN-៦៥២០ (មិនប្រក្រតី) ប្រគល់ឱ្យឈ្មោះ [redacted] ស្រីភ័ក្រ ភេទស្រី កើតឆ្នាំ១៩៩០ អាសយដ្ឋាន ភូមិទួលក្រសាំង ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ។

២-១-៥-ម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ផ្លាកលេខ កណ្ដាល ១Q -9099 (មិនប្រក្រតី) រឹបអូសជាសម្បត្តិរដ្ឋ។

២-១-៦-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ផ្លាកលេខ សៀមរាប ១X-៤៣៤៧ (មិនប្រក្រតី) រឹបអូសជាសម្បត្តិរដ្ឋ។

២-១-៧-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស ផ្លាកលេខ ភ្នំពេញ ១FH-៣០៧៣ (មិនប្រក្រតី) រឹបអូសជាសម្បត្តិរដ្ឋ។

២-១-៨-ម៉ូតូម៉ាក Honda dream c15 ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ ១BQ -១៦៥១ (មិនប្រក្រតី) រឹបអូសជាសម្បត្តិរដ្ឋ។

២-២-ប័ណ្ណ ប.ស.ស ឈ្មោះ [redacted] ភាន់ លេខ 1981-1918312-ព ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៣-ប័ណ្ណ ប.ស.ស ឈ្មោះ [redacted] សារ៉េត លេខ 2830816-0200956-ទ ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៤-កាត Wing មាន០២ លេខគណនីវីង 03371901 និងមួយទៀត លេខគណនីវីង លេខ 03964833 ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៥-អត្តសញ្ញាណប័ណ្ណមាន០៣ ឈ្មោះ [redacted] សារ៉េត លេខ 050984717 ,ឈ្មោះ [redacted] ឈៀវ លេខ 011343992, ឈ្មោះ ម៉ុន សុបញ្ញា លេខ 011401421 ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៦-ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ មានចំនួន០៥ (ឈ្មោះ [redacted] ហេងរដ្ឋា, ឈ្មោះ [redacted] សៀង, ឈ្មោះ [redacted] ស្រីស , ឡាច ស្រីកុល និងឈ្មោះ [redacted] សុបញ្ញា) ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៧-កាតចេញចូលរោងចក្រ ឈ្មោះ [redacted] សារ៉េត SW50045 ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៨-លោហៈធាតុពណ៌លឿង (កងដៃ) ៦កង និងលោហៈធាតុពណ៌ទឹកប្រាក់ ០១កង និងចិញ្ចៀន០២វង់ និងមួយទៀតមានដាំត្បូងពណ៌ស ចំនួន១៩គ្រាប់ ប្រគល់ឱ្យម្ចាស់ដើមវិញ។

២-៩-កាបូបដៃស្រីចំនួន០៣ និងកាបូបដៃប្រុសចំនួន៤ និងកាបូបធំស្ពាយពីក្រោយចំនួន០១ ប្រគល់ឱ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ និងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទទាំងអស់ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។

-ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

ថ្ងៃ..........ខែ..........ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល ថ្ងៃទី.......ខែ..............ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner